ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមណ្ឌលប្រតិបត្តិការភូមិភាគ ចំណុះមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៨២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ២៨១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន
- តាមសំណើរបស់ប្រធានមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១** ..

ត្រូវបានបង្កើត "មណ្ឌលប្រតិបត្តិការភូមិភាគ" ហៅកាត់ "ម.ប.ភ." ចំនួន ៦(ប្រាំមួយ) ចំណុះឱ្យមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន (ម.ប.ព.) ដើម្បីជាសេនាធិការផ្នែកប្រតិបត្តិការ និងបច្ចេកទេស

លើការងារស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានពាក់ព័ន្ធវិស័យសន្តិសុខជាតិ ក្នុងគោលដៅដើម្បីប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនានានៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់មណ្ឌលប្រតិបត្តិការភូមិភាគ
### ផ្នែកទី១
### រចនាសម្ព័ន្ធ

**មាត្រា២ ..**

មណ្ឌលប្រតិបត្តិការភូមិភាគ ទាំង ៦(ប្រាំមួយ) រួមមាន ដូចខាងក្រោម៖

១. មណ្ឌលប្រតិបត្តិការភូមិភាគពិសេស ហៅកាត់ "ម.ប.ភ.ព" មានសមត្ថកិច្ចសម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តកំពង់ឆ្នាំង។

២. មណ្ឌលប្រតិបត្តិការភូមិភាគទី១ ហៅកាត់ "ម.ប.ភ.១" មានសមត្ថកិច្ចសម្រាប់ភូមិសាស្ត្រខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តរតនៈគិរី និងខេត្តក្រចេះ។

៣. មណ្ឌលប្រតិបត្តិការភូមិភាគទី២ ហៅកាត់ "ម.ប.ភ.២" មានសមត្ថកិច្ចសម្រាប់ភូមិសាស្ត្រខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង និងខេត្តព្រៃវែង។

៤. មណ្ឌលប្រតិបត្តិការភូមិភាគទី៣ ហៅកាត់ "ម.ប.ភ.៣" មានសមត្ថកិច្ចសម្រាប់ភូមិសាស្ត្រខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង។

៥. មណ្ឌលប្រតិបត្តិការភូមិភាគទី៤ ហៅកាត់ "ម.ប.ភ.៤" មានសមត្ថកិច្ចសម្រាប់ភូមិសាស្ត្រខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។

៦. មណ្ឌលប្រតិបត្តិការភូមិភាគទី៥ ហៅកាត់ "ម.ប.ភ.៥" មានសមត្ថកិច្ចសម្រាប់ភូមិសាស្ត្រខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន។

**មាត្រា៣ ..**

មណ្ឌលប្រតិបត្តិការភូមិភាគនីមួយៗដឹកនាំដោយប្រធាន ១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន ម.ប.ព. ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន ម.ប.ព. និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន ម.ប.ព. ដែលត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន ម.ប.ព. បន្ទាប់ពីមានការយល់ព្រមពីនាយករដ្ឋមន្ត្រី។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលប្រតិបត្តិការភូមិភាគត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ម.ប.ព. បន្ទាប់ពីទទួលបានគោលការណ៍ឯកភាពពីនាយករដ្ឋមន្ត្រី។

អង្គការលេខរបស់មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## តួនាទី និងភារកិច្ច

**មាត្រា៤ ..**

មណ្ឌលប្រតិបត្តិការភូមិភាគ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការជូន ម.ប.ព. ក្នុងការស្រាវជ្រាវ ប្រមូល និងចងក្រងព័ត៌មានដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ ក្នុងគោលដៅប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនានា
- វិភាគព័ត៌មាន និងវាយតម្លៃអំពីសភាពការណ៍សន្តិសុខជាតិជូន ម.ប.ព. សម្រាប់ការដាក់ចេញនូវវិធានការចាំបាច់នានា សំដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនានា
- សហការស្រាវជ្រាវ និងប្រមូលព័ត៌មាន រាយការណ៍ជូន ម.ប.ព. ដើម្បីមានវិធានការប្រតិបត្តិការតាមច្បាប់
- សហការជាមួយស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងភាគីពាក់ព័ន្ធនានាក្នុងការស្រាវជ្រាវ និងប្រមូលព័ត៌មានដែលបម្រើឱ្យវិស័យសន្តិសុខជាតិ ការប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនានា
- គ្រប់គ្រង ចងក្រង រក្សាទុកទិន្នន័យ និងរក្សាការសំងាត់នូវរាល់ព័ត៌មានពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ ដែលស្រាវជ្រាវ និងប្រមូលបាន
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់ប្រធាន ម.ប.ព.។

**មាត្រា៥ ..**

មណ្ឌលប្រតិបត្តិការភូមិភាគ អនុវត្តការងារក្រោមការដឹកនាំបញ្ជាផ្ទាល់របស់ប្រធាន ម.ប.ព.។

## ជំពូកទី៣
## បុគ្គលិក និងថវិការបស់មណ្ឌលប្រតិបត្តិការភូមិភាគ

**មាត្រា៦ ..**

មន្ត្រីដែលបំពេញការងារនៅមណ្ឌលប្រតិបត្តិការភូមិភាគ គឺជាមន្ត្រីរាជការក្របខណ្ឌនៃទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល។ មណ្ឌលប្រតិបត្តិការភូមិភាគ អាចមានមន្ត្រីជាប់កិច្ចសន្យាតាមការចាំបាច់។

**មាត្រា៧ ..**

មណ្ឌលប្រតិបត្តិការភូមិភាគ ប្រើប្រាស់ថវិការបស់ ម.ប.ព. ដើម្បីបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋានដែលពាក់ព័ន្ធ ប្រធានមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

កន្លែងទទួល៖
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- ឯកសារ-កាលប្បវត្តិ